# ជំនួយបច្ចេកទេស ស្តីពីសហគមន៍ សិទ្ធិ និងយេនឌ័រ (ស៊ីអាជី ធីអេ)

# សំណួរដែលតែងតែត្រូវបានសួរជាញឹកញាប់




កម្មវិធីជំនួយបច្ចេកទេស ស្តីពី សហគមន៍ សិទ្ធិ និងយេនឌ័រ (ស៊ីអាជី ធីអេ) គឺជាកម្មវិធីដែលត្រូវបានបង្កើតឡើង ដើម្បីជួយដល់អង្គការសង្គមស៊ីវិល និងបណ្តាញសហគមន៍ ដើម្បីធ្វើឱ្យប្រាកដថា ឧបសគ្គនានាដែលមានទំនាក់ទំនងនឹងការចូលរួមរបស់សហគមន៍ សិទ្ធិមនុស្ស និងសមភាពយេនឌ័រ ត្រូវបានលើកឡើង និងឆ្លើយតប នៅក្នុងកញ្ចប់មូលនិធិ ដែលគាំទ្រដោយមូលនិធិសាកលដែលកំពុងអនុវត្តចាប់ពីខែមករា ឆ្នាំ២០២១ដល់ខែធ្នូឆ្នាំ២០២៣ តាមរយៈកម្មវិធីជំនួយបច្ចេកទេស។

## តើនរណាខ្លះអាចស្នើសុំបាននូវជំនួយបច្ចេកទេសនេះ?

- ◉ អង្គការ និងបណ្តាញក្រុមប្រឈមមុខខ្ពស់
- ◉ អង្គការ និងបណ្តាញក្រុមប្រឈមមុខខ្ពស់
- ◉ អង្គការ និងបណ្តាញស្រ្តី
- ◉ បណ្តាញ ឬអង្គការរបស់អ្នករស់នៅជាមួយមេរោគអេដស៍ /ឬរបេង/ឬគ្រុនចាញ់
- ◉ បណ្តាញឬអង្គការសង្គមស៊ីវិល ដែលដឹកនាំ ឬធ្វើការជាមួយក្រុម ឬសហគមន៍រងគ្រោះដទៃផ្សេងទៀត (ឧទាហរណ៍ ក្រុមចំណាកស្រុក ក្រុមជនភៀសខ្លួន ក្រុមកម្មកររ៉ែ)
- ◉ គណៈកម្មការសម្របសម្រួលប្រចាំប្រទេស(ស៊ីស៊ីអឹម)និងគណៈកម្មការសម្របសម្រួលថ្នាក់តំបន់ (អាស៊ីអឹម) តែក្នុងករណីដែលគម្រោងសំណើត្រូវបានផ្ញើមក និងរៀបចំក្នុងកិច្ចសហការជាមួយអង្គការ ឬ បណ្តាញឬអ្នកពាក់ព័ន្ធខាងលើ

## តើខ្ញុំអាចដាក់សំណើបាននៅពេលណា?

អ្នកអាចស្វែងរកជំនួយបច្ចេកទេសបាននៅគ្រប់ដំណាក់កាលណាមួយរបស់គម្រោងថវិកា ដែលមានសម្រាប់ឆ្នាំ២០២០ ដល់ឆ្នាំ ២០២២ ដោយអាចរកបានក្នុងដំណាក់កាលនៃការ អនុវត្តិគម្រោងថវិកា និងនៅពេលធ្វើការវាយតម្លៃ និងពិនិត្យគម្រោង។ កម្មវិធីជំនួយបច្ចេកទេស ក៏អាចផ្តល់ការគាំទ្រដល់ការចូលរួមរបស់សហគមន៍ នៅក្នុងដំណាក់កាលនៃការរៀបចំផែនការ អន្តរកាល និងនិរន្តរភាព (អេសធីស៊ី)ឬក្នុងដំណើរការដទៃផ្សេងទៀតរបស់មូលនិធិសាកល ដូចជាក្នុងពេលរៀបចំផែនការយុទ្ធសាស្រ្តជាតិ (អិនអេសភី) ជាដើម។

## តើប្រភេទជំនួយបច្ចេកទេសអ្វីខ្លះ ដែលខ្ញុំអាចស្នើសុំបាន?

- ◉ ការប៉ាន់ប្រមាណតម្រូវការ និងការវិភាគស្ថានភាព
- ◉ ការចូលរួមក្នុងដំណើរការនៃកិច្ចពិភាក្សាក្នុងប្រទេស
- ◉ គាំទ្រដល់ការរៀបចំគម្រោង និងការចាត់ចែងការអនុវត្តិ

ជំនួយបច្ចេកទេសផ្នែកសហគមន៍ សិទ្ធិ និងយេនឌ័រ មិនអាចផ្តល់ការគាំទ្រ ដល់ការពង្រឹងគណៈកម្មការសម្របសម្រួលប្រចាំប្រទេស ឬផ្តល់ការគាំទ្ររយៈពេលយូរដល់ការពង្រឹងសមត្ថភាពរបស់បណ្តាញ និងរបស់អង្គការសង្គមស៊ីវិល ឬផ្តល់ការគាំទ្រដល់ការបង្កើតឧបករណ៍ដោយឡែក ដែលមិនផ្តោត និងយកចិត្តទុកដាក់ទៅលើការចូលរួមរបស់សហគមន៍ និងមិនផ្តោតលើការសរសេរគំរោងសំណើសុំមូលនិធិនោះទេ។

## នរណាខ្លះនឹងផ្តល់ជំនួយបច្ចេកទេស?

នាយកដ្ឋាន ទទួលខុសត្រូវផ្នែកសហគមន៍ សិទ្ធិ និងយេនឌ័រ របស់មូលនិធិសាកល បានអនុម័តិ ទុកជាមុននូវ អ្នកផ្តល់ជំនួយបច្ចេកទេសចំនួន ២៦ស្ថាប័ន ដែលអាចមានសមត្ថភាពពេញលេញក្នុងការផ្តល់ជំនួយបច្ចេកទេស។ ដោយហេតុថាអ្នកផ្តល់ជំនួយបច្ចេកទេស គឺប្រហែលជាមិនមកពីក្នុងតំបន់ តែក្នុងករណីភាគច្រើន(ប្រសិនបើចាំបាច់) អ្នកផ្តល់ជំនួយបច្ចេកទេស មកពីក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក នឹងត្រូវបានជួល។ អ្នកអាចស្នើសុំអ្នកផ្តល់ជំនួយបច្ចេកទេសណាម្នាក់ដែលអ្នកចង់បានពីបញ្ជីឈ្មោះអ្នកផ្តល់ជំនួយបច្ចេកទេសប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៅក្នុងសំណើសុំរបស់អ្នក តែនាយកដ្ឋាន ទទួលខុសត្រូវផ្នែកសហគមន៍ សិទ្ធិ និងយេនឌ័រ របស់មូលនិធិសាកល គឺជាអ្នកធ្វើការសម្រេចចុងក្រោយ។

## បញ្ជីឈ្មោះអ្នកផ្តល់ជំនួយបច្ចេកទេសផ្នែកសហគមន៍ សិទ្ធិ និងយេនឌ័រ ដែលបានអនុម័តិទុកជាមុន

- AIDS & Rights Alliance for Southern Africa (ARASA)
- AIDS Strategy, Advocacy and Policy (ASAP)
- Alliance Consultancy*
- APCOM Foundation*
- Asia Pacific Network of People Living with HIV (APN+)*
- Center for Health Policies and Studies
- Coact*
- Coalition PLUS
- Eurasian Coalition on Health, Rights, Gender and Sexual Diversity (ECOM)
- Frontline AIDS*
- HIV, Accelerated, Real-time, Versatile, Equitable, Safe response, and TB response - Technical Advisory (HARVEST-TA) consortium
- HIV Legal Network
- Hivos
- Harm Reduction International*
- International Community of Women Living with HIV Eastern Africa (ICWEA)
- Initiatives Conseil International-Santé (ICI SANTE)
- International Council of AIDS Service Organisations (ICASO)*
- Kenya NGO Alliance Against Malaria (KeNAAM)*
- Moldovan Institute for Human Rights (IDOM)
- Mainline Foundation*
- Community-led Assistance for Peer Engagement (CAPE)*
- PATA, Y+ Global and UNYPA
- PATH*
- Partners in Health
- Resource Group for Education and Advocacy for Community Health (REACH)*
- Stitching TB Europe Foundation Coalition

*អ្នកផ្តល់ជំនួយបច្ចេកទេសសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក

## តើខ្ញុំអាចដាក់ពាក្យសុំតាមវិធីណា?

ដើម្បីដាក់ពាក្យសុំជំនួយបច្ចេកទេស អ្នកត្រូវទាញទម្រង់ពាក្យសុំ ដោយចូលទៅក្នុងតំណភ្ជាប់នេះ https://apcaso.org/apcrg/support/. ប្រសិនបើត្រូវការជំនួយ សូមទាក់ទងលោក Jeff Acaba ដែល ជាអ្នកទទួលខុសត្រូវក្នុងការសម្របសម្រួលកិច្ចការពាក់ព័ន្ធនឹងយន្តការ សហគមន៍ សិទ្ធិ និង យេនឌ័រ ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក តាមរយៈអ៊ីម៉ែល jeffacaba@apcaso.org ហើយយើងនឹង ជួយដោយរីករាយ។

នៅពេលដែលអ្នកបានបំពេញពាក្យស្នើសុំរួចរាល់សូមបញ្ជូនទម្រង់ព័ត៌មានដែលបានបំពេញនោះ ទៅកាន់អាសយដ្ឋានអ៊ីម៉ែល crgta@theglobalfund.org

អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍ (ខាណា) គឺជាអង្គការសង្គមស៊ីវិលខ្មែរក្នុងស្រុក ដែលប្រាថ្នាចង់បានប្រទេសកម្ពុជាមួយដែលគាំទ្រ និងពង្រឹងភាពជាម្ចាស់ និងភាពអង់អាចរបស់សហគមន៍ ដែលប្រជាពលរដ្ឋទាំងអស់ទទួលបានប្រកបដោយ សមធម៌ នូវសេវាសុខភាព និងសេវាពាក់ព័ន្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលមានគុណភាព និងឱកាសអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ បេសកកម្ម របស់អង្គការខាណា គឺបន្តជាអ្នកនាំមុខ ក្នុងការឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងពេលជាមួយ នឹងការឆ្លើយតបទៅនឹងតម្រូវការទូលំទូលាយ ផ្នែកសុខភាព និងការអភិវឌ្ឍន៍។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង **khana@khana.org.kh**

KHANA
UNITED FOR A STRONGER COMMUNITY

**APCASO** គឺជាបណ្តាញអង្គការសង្គមស៊ីវិលប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដែលផ្តោតលើការងារ សុខភាព យុត្តិធម៌សង្គម និងសិទ្ធិមនុស្ស។ **APCASO** នាពេលបច្ចុប្បន្ន គឺជាអ្នកគ្រប់ គ្រង និងទទួលខុសត្រូវ យន្តការសហគមន៍ សិទ្ធិ និងយេនឌ័រ ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដែលមានភារកិច្ចក្នុងការចែករំលែកព័ត៌មានថ្មីៗដែលមានសារសំខាន់ និងជួយក្នុងការបង្កើតឧបករណ៍នានា និងផ្តល់ជំនួយបច្ចេកទេស ដើម្បីលើកកំពស់ នូវការដាក់បញ្ចូល សហគមន៍ សិទ្ធិ និងយេនឌ័រ ក្នុងកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់ របស់មូលនិធិសាកល នៅក្នុងតំបន់។

APCASO
Strengthening community systems. Advancing human rights.

apcrg
The Asia-Pacific Platform on Communities, Rights & Gender

www.apcaso.org/apcrg/ APCASO